**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៣ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំការចងសម្ព័ន្ធមេត្រីភាព
## រវាងអង្គភាពកងទ័ព ជាមួយស្ថាប័ន អង្គភាពស៊ីវិល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណូមពរចាំបាច់នៃការងារ

**សម្រេច**

**ប្រការ ១ :** ត្រូវបានរៀបចំឱ្យមានការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព ជាមួយស្ថាប័ន អង្គភាពស៊ីវិល ដូចមានខាងក្រោមនេះ :

១-បញ្ជាការដ្ឋានកងទ័ពជើងគោក សម្ព័ន្ធមេត្រីជាមួយ រាជាយស្ម័យយានកម្ពុជា

| | |
|---|---|
| ២-កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សម្ព័ន្ធមេត្រីជាមួយ ភ្នាក់ងារនាវាចរណ៍កាំសាប |
| ៣-បញ្ជាការដ្ឋានកងទ័ពជើងទឹក | សម្ព័ន្ធមេត្រីជាមួយ កំពង់ផែស្វយ័តក្រុងភ្នំពេញ |
| ៤-បញ្ជាការដ្ឋានកងទ័ពជើងអាកាស | សម្ព័ន្ធមេត្រីជាមួយ នាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម |
| ៥-កងពលតូចលេខ ៧០ | សម្ព័ន្ធមេត្រីជាមួយ ក្រសួងធនធានទឹក និងឧតុនិយម និងចំការកៅស៊ូចំការអណ្តូង |
| ៦-បញ្ជាការដ្ឋានកាំភ្លើងធំ | សម្ព័ន្ធមេត្រីជាមួយ អគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៧-បញ្ជាការដ្ឋានរថក្រោះ | សម្ព័ន្ធមេត្រីជាមួយ អង្គភាពកំពង់ចំលងអ្នកលឿង |
| ៨-បញ្ជាការដ្ឋានបញ្ជូនសារ | សម្ព័ន្ធមេត្រីជាមួយ អង្គភាពទូរគមនាគមន៍កម្ពុជា |
| ៩-បញ្ជាការដ្ឋានការពារអាកាស | សម្ព័ន្ធមេត្រីជាមួយ រដ្ឋបាលព្រៃឈើ ។ |

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន អង្គភាព មេបញ្ជាការអង្គភាព និងគ្រប់ក្រសួង ស្ថាប័ន អង្គភាព ដែលមានចែងក្នុងប្រការ ១ និងមានការពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ